ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាអាជ្ញាកណ្តាល
THE ARBITRATION COUNCIL

**លេខ និង ឈ្មោះសំណុំរឿង : ២៣/១១-ជូន តិចថាយល៍**

**កាលបរិច្ឆេទនៃសេចក្តីបង្គាប់ : ថ្ងៃទី០៩ ខែមីនា ឆ្នាំ២០១១**

# សេចក្តីបង្គាប់អាជ្ញាកណ្តាល

(ធ្វើឡើងស្របតាមមាត្រា ៣១៣ នៃច្បាប់ស្តីពីការងារ)

## សមាសភាពក្រុមអាជ្ញាកណ្តាល

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីនិយោជក: **ឈីវ ភិរម្យ**

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីកម្មករនិយោជិត: **ស៊ីន គឹមស៊ាន**

ប្រធានក្រុមអាជ្ញាកណ្តាលជ្រើសរើសឡើងដោយអាជ្ញាកណ្តាលទាំងពីរខាងលើ: **ប៉ែន ប៊ុនឈា**

## ភាគីនៃវិវាទ

**១- ភាគីនិយោជក**

ឈ្មោះ : **ក្រុមហ៊ុន ជូន តិចថាយល៍**

អាសយដ្ឋាន : មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ

ទូរស័ព្ទ : ០១២ ៥៤១ ៨៥១ ទូរសារ : គ្មាន

តំណាងភាគីនិយោជក :

- លោក តាំង គីសាយ រដ្ឋបាល

**២- ភាគីកម្មករនិយោជិត**

ឈ្មោះ : **- សហជីពសេរីកម្មករនៃព្រះរាជាណាចក្រកម្ពុជា**

**- សហជីពសេរីកម្មករ ក្រុមហ៊ុន ជូន តិចថាយល៍**

អាសយដ្ឋាន : មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ

ទូរស័ព្ទ : ០៨៨ ៨៣៣ ៥៥៥៥ ទូរសារ : គ្មាន

តំណាងកម្មករនិយោជិត: **អវត្តមាន**

ផ្ទះលេខ ៧២ ផ្លូវលេខ ៥៩២ (កែងផ្លូវលេខ ៣២៧) សង្កាត់បឹងកក់ ២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ។ ទូរស័ព្ទ/ទូរសារ: ៨៥៥-២៣ ៨៨១ ៨២៤
No. 72, Street 592 (corner of St. 327), Sangkat Boeung Kak II, Khan Tuol Kork, Phnom Penh • Tel/Fax: 855-23 881 824
E-mail: secretariat@arbitrationcouncil.org • Website: www.arbitrationcouncil.org

## បញ្ហាក្នុងវិវាទ

(នៅក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា)

១- សហជីពសេរីកម្មករប្រចាំក្រុមហ៊ុន ទាមទារឱ្យក្រុមហ៊ុនបើកប្រាក់ឈ្នួលជូនកម្មករឱ្យបានមុនថ្ងៃឈប់សម្រាក។ ដោយឡែកភាគីក្រុមហ៊ុនបញ្ជាក់ថា ក្រុមហ៊ុនសុំអនុវត្តទៅតាមគោលការណ៍ចាស់ដដែល។

២- សហជីពសេរីកម្មករប្រចាំក្រុមហ៊ុន ទាមទារឱ្យក្រុមហ៊ុនផ្តល់ប្រាក់ធ្វើដំណើរ ឬប្រាក់ថ្លៃឈ្នួលផ្ទះ ក្នុងមួយខែ ប្រាំដុល្លារ។ ដោយឡែកភាគីក្រុមហ៊ុនបញ្ជាក់ថា ក្រុមហ៊ុនពុំមានលទ្ធភាពផ្តល់ជូនឡើយ។

៣- សហជីពសេរីកម្មករប្រចាំក្រុមហ៊ុន ទាមទារឱ្យក្រុមហ៊ុនផ្តល់ម៉ោងជូនកម្មករនៅក្រុម២ ក្រុម៥ និងក្រុម៨ ជាន់ទី២ ផ្នែកអ៊ុត បត់ ច្រកឡូ ដែលបានធ្វើកូដកម្មកន្លងមក។ ដោយឡែកភាគីក្រុមហ៊ុនបញ្ជាក់ថា ក្រុមហ៊ុនមិនអាចផ្តល់ជូនតាមការទាមទារខាងលើបានទេ។

៤- សហជីពសេរីកម្មករប្រចាំក្រុមហ៊ុន ទាមទារឱ្យក្រុមហ៊ុនអនុវត្តការងារផ្នែកតុកាត់ដូចពីមុន។ ដោយឡែកភាគីក្រុមហ៊ុនបញ្ជាក់ថា ការរៀបចំការងារផ្នែកតុកាត់ គឺជាសិទ្ធិចាត់ចែងរបស់ក្រុមហ៊ុន។

៥- សហជីពសេរីកម្មករប្រចាំក្រុមហ៊ុន ទាមទារឱ្យក្រុមហ៊ុនឈប់កាត់សមាជិករបស់សហជីពសេរីកម្មករប្រចាំក្រុមហ៊ុនដោយគ្មានការឆ្លងកាត់ពីថ្នាក់ដឹកនាំសហជីព។ ដោយឡែកភាគីក្រុមហ៊ុនបញ្ជាក់ថា ក្រុមហ៊ុនអនុវត្តទៅតាមច្បាប់ស្តីពីការងារ និងប្រកាសលេខ ៣០៥ សកបយ។

គួរបញ្ជាក់ថា នៅថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០១១ អ្នកផ្សះផ្សាវិវាទការងារបានចុះទៅដល់ទីតាំងក្រុមហ៊ុនដើម្បីធ្វើការដោះស្រាយ តែភាគីសហជីពសេរីកម្មករប្រចាំក្រុមហ៊ុនមិនបានចូលរួមដោះស្រាយឡើយ។ ទន្ទឹមនឹងនោះ អ្នកផ្សះផ្សាបានធ្វើលិខិតអញ្ជើញភាគីទាំងពីរមកធ្វើការដោះស្រាយនៅនាយកដ្ឋានវិវាទការងារ នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ នៅថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០១១ វេលាម៉ោង ០៨:០០ តាមរយៈលិខិតលេខ ០៧៨ កប/អក/វក ចុះថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០១១ តែភាគីសហជីពនៅតែមិនមកចូលរួមដោះស្រាយ ដោយពុំបានបញ្ជាក់នូវមូលហេតុឱ្យបានច្បាស់លាស់ឡើយ។ ដូច្នេះអាចបញ្ជាក់ថា ភាគីនេះអនុវត្តផ្ទុយទៅនឹងមាត្រា ៣០៦ នៃច្បាប់ស្តីពីការងារ។ នៅរសៀលថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០១១ ដោយមានការអញ្ជើញពីភាគីក្រុមហ៊ុន អ្នកផ្សះផ្សាបានចុះទៅធ្វើការដោះស្រាយដល់ទីតាំងក្រុមហ៊ុនជាថ្មីម្តងទៀត ដោយភាគីទាំងពីរឯកភាពចូលរួមផ្សះផ្សា ដោយការចរចាពុំបានលទ្ធផលវិជ្ជមាន ភាគីសហជីពសេរីកម្មករប្រចាំក្រុមហ៊ុនបានដើរចេញនៅពេលដែលអង្គប្រជុំពុំទាន់បានចប់សព្វគ្រប់ គឺមិននៅរង់ចាំចុះហត្ថលេខាលើកំណត់ហេតុផ្សះផ្សាឡើយ។

## អំណាចយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល

ក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលអំណាចក្នុងការចេញសេចក្តីបង្គាប់នេះ ដោយយោងតាមជំពូកទី១២ ផ្នែកទីពីរ(ខ)(មាត្រា ៣០៩ ដល់ ៣១៧) នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ

THE ARBITRATION COUNCIL

០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ និងប្រកាសស្តីពីការតែងតាំងសមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ១៣៣ កប/ប្រក ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០១០ ( អាណត្តិទី៨) ។

ការព្យាយាមផ្សះផ្សាវិវាទការងាររួម ដែលជាកម្មវត្ថុនៃសេចក្តីបង្គាប់នេះ ត្រូវបានធ្វើឡើងស្របតាមជំពូកទី១២ ផ្នែកទី ២ ( ក) នៃច្បាប់ស្តីពីការងារ ។ ប៉ុន្តែការផ្សះផ្សានោះ ភាគីទាំងពីរមិនបានឯកភាពសះជានឹងគ្នាឡើយ ហើយរបាយការណ៍ស្តីអំពីការមិនសះជា លេខ ១៨៤ កប/អក/វក ចុះថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០១១ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០១១ ។

## សវនាការ និង សង្ខេបនីតិវិធី

**ទីកន្លែងសវនាការ** : ក្រុមប្រឹក្សាអាជ្ញាកណ្តាល ភូមិគ្រឹះលេខ ៧២ ផ្លូវលេខ ៥៩២ កាច់ជ្រុងផ្លូវលេខ ៣២៧ ( ទល់មុខវិទ្យាល័យឥន្ទ្រទេវី), សង្កាត់បឹងកក់ ២, ខណ្ឌទួលគោក, រាជធានីភ្នំពេញ ។

**កាលបរិច្ឆេទសវនាការ** : ថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ២០១១ ( វេលាម៉ោង ១៤:០០ នាទី រសៀល ) ។

## បញ្ហានៃនីតិវិធីៈ

នៅថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០១១ នាយកដ្ឋានវិវាទការងារ បានទទួលបណ្តឹងតាមទូរស័ព្ទពីក្រុមហ៊ុន ជូន តិចថាយ៍ ស្តីពីកម្មករនិយោជិតផ្នែកតុកាត់ដែលដឹកនាំដោយសហជីពសេរីកម្មករប្រចាំរោងចក្រធ្វើកូដកម្មទាមទារសុំឱ្យក្រុមហ៊ុនកែលំអលក្ខខណ្ឌការងារមួយចំនួន។ បន្ទាប់ពីបានទទួលបណ្តឹងនេះភ្លាម នាយកដ្ឋានវិវាទការងារបានចាត់មន្ត្រីធ្វើការផ្សះផ្សាវិវាទការងាររួមនេះ នៅថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០១១ ដោយទទួលបានលទ្ធផលមិនសះជានឹងគ្នាចំនួន ០៥ ចំណុច លើការទាមទារចំនួន ០៥ ចំណុច។ ចំណុចមិនសះជាចំនួន ០៥ ចំណុចនេះ បានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០១១ តាមរយៈរបាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន ជូន តិចថាយល៍ លេខ ១៨៤ កប/អក/វក ចុះថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០១១។

បន្ទាប់ពីបានទទួលសំណុំរឿងរួចមក លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល បានធ្វើការកោះអញ្ជើញភាគីនិយោជក និងភាគីកម្មករនិយោជិតប្រចាំរោងចក្រមកសវនាការ និងធ្វើការផ្សះផ្សាលើករណីមិនសះជាចំនួន ០៥ ចំណុចនេះ នៅថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១១ វេលាម៉ោង ១៤:០០ នាទី រសៀល ប៉ុន្តែភាគីកម្មករនិយោជិតមិនបានមកចូលរួមសវនាការតាមការអញ្ជើញរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលទេ។ ភាគីកម្មករនិយោជិតបានសរសេរលិខិតមួយ ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១១ ដោយបញ្ជាក់កម្មវត្ថុថា *"មិនចូលរួមដោះស្រាយតាមសំណើរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល"* ។ ចំណែកឯ ភាគីនិយោជកវិញបានមកចូលរួមសវនាការ តាមការកោះហៅរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល។ ហេតុនេះហើយ ក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងធ្វើការពិចារណា និងសម្រេចលើចំណុចវិវាទក្នុងសំណុំរឿងនេះ ដូចខាងក្រោម :

**ភស្តុតាង**

សាក្សី និង អ្នកជំនាញក្រៅពីភាគី : គ្មាន

**ឯកសារ ភស្តុតាង ដែលក្រុមអាជ្ញាកណ្តាលយកមកពិចារណាមាន**

**ក- ឯកសារបានទទួលពីភាគីនិយោជក : គ្មាន**

**ខ- ឯកសារបានទទួលពីភាគីកម្មករនិយោជិត :**

១- លិខិតលេខ ២០៤/១១ សសកពក ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១១ របស់សហជីពសេរីកម្មករនៃព្រះរាជាណាចក្រកម្ពុជា គោរពជូន ប្រធានលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល ស្តីពីការមិនចូលរួមដោះស្រាយតាមសំណើររបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល ។

២- ដីកាកោះ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ សំណុំរឿងព្រហ្មទណ្ឌលេខ ៤២៦ ចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០១១ អញ្ជើញឈ្មោះ ផេង ជូ ។

**គ- ឯកសារបានទទួលពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

១- របាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន ជូន តិចថាយល៏ លេខ ១៨៤ កប/អក/វក ចុះថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០១១ ។

២- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមរបស់ក្រុមហ៊ុន ជូន តិចថាយល៏ ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ ២០១១ ។

**ឃ- ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល**

១- លិខិតលេខ ១២៨ កប/អក/វក/លកអ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១១ របស់លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល ជំរាបមក លោកស្រីប្រធានសហជីពសេរីកម្មករ នៃក្រុមហ៊ុន ជូន តិចថាយល៏ ស្តីពីការជ្រើសរើសអាជ្ញាកណ្តាល ។

២- កំណត់ហេតុស្តីពីការចាប់ឆ្នោតជ្រើសរើសអាជ្ញាកណ្តាល ពីបញ្ជីអាជ្ញាកណ្តាលស្នើដោយសហជីពកម្មករនិយោជិត ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១១ ។

៣- លិខិតអញ្ជើញភាគីនិយោជកចូលរួមសវនាការលេខ ១៣៥ កប/អក/វក/លកអ. ចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០១១ ។

៤- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមសវនាការលេខ ១៣៦ កប/អក/វក/លកអ. ចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០១១ ។

**អង្គហេតុ**

- គ្មាន

**ហេតុផលនៃសេចក្តីសម្រេចៈ**

នៅក្នុងសំណុំរឿងនេះ ភាគីសហជីព និងកម្មករនិយោជិត រោងចក្រ ជូន តិចថាយល៏ មិនបានចូលរួម នៅក្នុងនីតិវិធីរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលតាមការអញ្ជើញទេ។ ភាគីកម្មករនិយោជិតគ្រាន់តែបានបញ្ជាក់ប្រាប់ថា មិនមកចូលរួមនីតិវិធីរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល តាមរយៈលិខិត ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១១ ដោយបញ្ជាក់កម្មវត្ថុថា " *មិនចូលរួមដោះស្រាយតាមសំណើរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល* "។

ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណាលើសំណុំរឿងនេះ ដូចខាងក្រោមៈ

វិធាន ៤.៧ នៃវិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល ឧបសម្ព័ន្ធនៃប្រកាសលេខ ០៩៩ សកបយ. ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ ចែងថា "*ប្រសិនបើភាគីណាមួយមិនបានបង្ហាញខ្លួន ឬមិនមានអ្នកតំណាងក្នុងដំណើរការអាជ្ញាកណ្តាល ក្រុមអាជ្ញាកណ្តាលអាចបន្តដំណើរការរបស់ខ្លួន ក្នុងអវត្តមានរបស់ភាគីនោះ ឬអាចបញ្ចប់ដំណើរការអាជ្ញាកណ្តាល ដោយចេញជាសេចក្តីបង្គាប់...* "។

ប្រកាសលេខ ០៩៩ សកបយ. ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ ស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាល ប្រការ ២១ ចែងថា "*ក្នុងករណីភាគីណាមួយបានទទួលការអញ្ជើញត្រឹមត្រូវហើយ តែបែរជាខកខានមិនបានមកបង្ហាញខ្លួននៅចំពោះមុខក្រុមអាជ្ញាកណ្តាល ដោយគ្មានបង្ហាញមូលហេតុត្រឹមត្រូវ ក្រុមអាជ្ញាកណ្តាលអាចបន្តដំណើរការរបស់ខ្លួនក្នុងពេល ដែលភាគីនោះអវត្តមាន ឬអាចបញ្ចប់ដំណើរការអាជ្ញាកណ្តាល ដោយចេញជាសេចក្តីបង្គាប់* "។

នៅក្នុងសំណុំរឿងលេខ ១៦/០៧-ឡូទូសតី និងលេខ ២៧/០៧-អ៊ីម និង វ៉េ ៣ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានបកស្រាយប្រការ ២១ ខាងលើនេះថា មានលក្ខខណ្ឌបី ដែលត្រូវបំពេញ ដើម្បីឱ្យក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចបិទសំណុំរឿងបាន "*លក្ខខណ្ឌទី១ : ភាគីត្រូវបានជូនដំណឹងដោយត្រឹមត្រូវ លក្ខខណ្ឌទី២ : ភាគីមិនបានបង្ហាញខ្លួននៅក្នុងសវនាការ និងលក្ខខណ្ឌទី៣ : ភាគីមិនបានផ្តល់មូលហេតុត្រឹមត្រូវសម្រាប់ការមិនបង្ហាញខ្លួន* "។

យោងតាម វិធាន ៤.៧ នៃវិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល ឧបសម្ព័ន្ធនៃប្រកាសលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ ប្រការ ២១ នៃប្រកាសលេខ ០៩៩ សកបយ. ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ ស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាល និងការយល់ឃើញរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងមុនៗខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលក្នុងសំណុំរឿងនេះ យល់ឃើញថា ក្រុមអាជ្ញាកណ្តាលសម្រេចបិទសំណុំរឿង ទៅតាមលក្ខខណ្ឌទាំងបីនោះ គឺ លក្ខខណ្ឌទី១ : ភាគីបានទទួលការអញ្ជើញត្រឹមត្រូវ លក្ខខណ្ឌទី២ : ភាគីខកខានមិនបានមកបង្ហាញខ្លួននៅចំពោះមុខក្រុមអាជ្ញាកណ្តាល និងលក្ខខណ្ឌទី៣ : ភាគីមិនបានផ្តល់មូលហេតុត្រឹមត្រូវសម្រាប់ការមិនបង្ហាញខ្លួន។

ហេតុនេះហើយ ក្នុងករណីនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងពិចារណាថា តើលក្ខខណ្ឌទាំងបីនេះ ត្រូវបានបំពេញដែរ ឬទេ?

**លក្ខខណ្ឌទី ១ : ភាគីត្រូវបានទទួលការអញ្ជើញត្រឹមត្រូវ**

មន្ត្រីលេខាធិការដ្ឋានបានទំនាក់ទំនងទៅកាន់ភាគីកម្មករនិយោជិត ជូនដំណឹងពីសវនាការអាជ្ញាកណ្តាល ប៉ុន្តែភាគីកម្មករនិយោជិតបានបញ្ជាក់ថា មិនមកចូលរួមសវនាការទេ។ ជាក់ស្តែងភាគីកម្មករនិយោជិតបានសរសេរលិខិត ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១១ ដោយបញ្ជាក់កម្មវត្ថុថា *"មិនចូលរួមដោះស្រាយតាមសំណើ របស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល"*។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា ភាគីពិតជាទទួលបានការអញ្ជើញត្រឹមត្រូវពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល ឱ្យចូលរួមសវនាការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលពិតប្រាកដមែន។ **ហេតុនេះ លក្ខខណ្ឌទី ១ ត្រូវបានបំពេញ។**

**លក្ខខណ្ឌទី ២ : ភាគីខកខានមិនបានមកបង្ហាញខ្លួននៅចំពោះមុខក្រុមអាជ្ញាកណ្តាល**

ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ពាក្យ *"បង្ហាញខ្លួននៅចំពោះមុខក្រុមអាជ្ញាកណ្តាល"* នៅក្នុងប្រការ ២១ នៃប្រកាស លេខ ០៩៩ សកបយ. ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ ស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាលនេះ មានន័យថា ភាគីត្រូវតែចូលរួមដំណើរការសវនាការអាជ្ញាកណ្តាល តាំងពីដើមរហូតដល់ចប់សព្វគ្រប់។

ដំណើរការសវនាការអាជ្ញាកណ្តាល ដែលមានបួនដំណាក់កាល ដូចជា:

ក-ដំណាក់កាលណែនាំខ្លួន និងពន្យល់អំពីទំនាស់ផលប្រយោជន៍

ខ-ដំណាក់កាលពន្យល់អំពីនីតិវិធី និងបញ្ជាក់បញ្ហានៃវិវាទ

គ-ដំណាក់កាលផ្សះផ្សា បើភាគីយល់ព្រមឱ្យក្រុមប្រឹក្សាអាជ្ញាកណ្តាលផ្សះផ្សាឡើងវិញ

ឃ-និងដំណាក់កាលសវនាការដល់អង្គសេចក្តី

ក្នុងករណីនេះ ភាគីសហជីព និងកម្មករនិយោជិត មិនបានចូលរួមនៅគ្រប់ដំណាក់កាលទាំងអស់នៃនីតិវិធីរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលក៏កត់សំគាល់ឃើញថា ភាគីកម្មករនិយោជិតនេះផ្ទាល់ក៏មិនបានមកចូលរួមជ្រើសរើសអាជ្ញាកណ្តាលផងដែរ។ ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ភាគីសហជីព និងកម្មករនិយោជិត មិនបានបង្ហាញខ្លួននៅចំពោះមុខក្រុមប្រឹក្សាអាជ្ញាកណ្តាល តាមខ្លឹមសារនៃលក្ខខណ្ឌទី២ នៃប្រការ ២១ ខាងលើនេះទេ។ **ហេតុនេះហើយ លក្ខខណ្ឌទី ២ ក៏ត្រូវបាន បំពេញដែរ។**

**លក្ខខណ្ឌទី ៣ : ភាគីមិនបានផ្តល់មូលហេតុត្រឹមត្រូវសម្រាប់ការមិនបង្ហាញខ្លួន**

ក្នុងករណីនេះ ភាគីសហជីព និងកម្មករនិយោជិត មិនបានផ្តល់ហេតុផលណាមួយសម្រាប់ការមិនចូលរួមសវនាការនេះទេ ពីព្រោះភាគីបានបញ្ជាក់ក្នុងលិខិត ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១១ ថា មិនមកចូលរួមដោះស្រាយនៅក្រុមប្រឹក្សាអាជ្ញាកណ្តាលទេ។ លើសពីនេះទៀត ភាគីកម្មករនិយោជិតបានបញ្ជាក់ថា ភាគីកម្មករនិយោជិតមិនមកចូលរួមសវនាការនេះទេ ហើយទុកឱ្យក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចតាមនីតិវិធីចុះ។ ចំណែកឯភាគីក្រុមហ៊ុនបានអញ្ជើញមកចូលរួមក្នុងសវនាការតាមកាលកំណត់។ ហេតុនេះហើយ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ ឃើញថា

THE ARBITRATION COUNCIL

**ភាគីសហជីព កម្មករនិយោជិតមិនបានផ្ដល់មូលហេតុត្រឹមត្រូវសម្រាប់ការមិនបង្ហាញខ្លួននេះទេ។ ហេតុនេះហើយ លក្ខខណ្ឌទី ៣ ក៏ត្រូវបានបំពេញដែរ។**

ដូច្នេះ ជាសរុបមក លក្ខខណ្ឌទាំងបី ដែលមានចែងក្នុងប្រការ ២១ ខាងលើ ត្រូវបានបំពេញ។

បន្ថែមពីលើនេះទៀត នៅក្នុងសំណុំរឿងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលបានផ្ដល់ឱកាសគ្រប់គ្រាន់ដល់សហជីពសេរីកម្មករនៃរោងចក្រ ជូន តិចថាយល័ ដែលជាភាគីដើមបណ្ដឹងក្នុងការធ្វើការការពារចំពោះការទាមទាររបស់កម្មករនិយោជិត ដែលពឹងពាក់ខ្លួនតាមនីតិវិធីច្បាប់ស្ដីពីការងារ។ ប៉ុន្តែ ភាគីកម្មករនិយោជិតបានជ្រើសរើសការមិនចូលរួមនៅក្នុងដំណើរការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្ដាល។ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលយល់ឃើញថា ភាគីកម្មករនិយោជិតគឺមានចេតនាមិនចូលរួមដោះស្រាយជំលោះរបស់ ខ្លួនជាមួយនិយោជកតាមនីតិវិធីដែលច្បាប់តំរូវនោះឡើយ។

ជាទូទៅ ដើមបណ្ដឹងមានកាតព្វកិច្ចផ្ដល់ហេតុផល និងភស្ដុតាងនៅចំពោះមុខក្រុមប្រឹក្សាអាជ្ញាកណ្ដាលដើម្បីការពារបណ្ដឹងរបស់ខ្លួន។ ប៉ុន្តែក្នុងសំណុំរឿងនេះ ភាគីសហជីព និងកម្មករនិយោជិត ដែលជាភាគីដើមបណ្ដឹងមិនបានផ្ដល់នូវហេតុផល និងភស្ដុតាង ដើម្បីការពារបណ្ដឹងរបស់ខ្លួនទេ។ ក្នុងករណីភាគីដើមបណ្ដឹងមិនចូលរួមក្នុងសវនាការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្ដាល ធ្វើឱ្យភាគីបាត់បង់ឱកាសក្នុងការផ្ដល់ហេតុផល និងភស្ដុតាង ដើម្បីការពារ និងគាំទ្រការទាមទាររបស់ខ្លួន។ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលចាត់ទុកថា នេះជាការបោះបង់បណ្ដឹងរបស់ខ្លួន។ ការសម្រេចចិត្តបែបនេះ គឺមិនបានបង្ហាញពីសុឆន្ទៈ ដោយសុទ្ធចិត្តរបស់ភាគីកម្មករនិយោជិត ក្នុងការយកវិវាទការងាររបស់ខ្លួនមកដោះស្រាយនៅចំពោះមុខក្រុមប្រឹក្សាអាជ្ញាកណ្ដាលនោះឡើយ។

ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលសម្រេចបិទសំណុំរឿងលេខ ២៣/១១- ជូន តិចថាយល័នេះ។

យោងតាមហេតុផលដូចបានបញ្ជាក់ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលសម្រេចដូចតទៅ :

## សម្រេច និង បង្គាប់

- សម្រេចបិទសំណុំរឿងលេខ ២៣/១១-ជូន តិចថាយល័។

**ហត្ថលេខារបស់សមាជិកក្រុមអាជ្ញាកណ្ដាល**

**អាជ្ញាកណ្ដាលជ្រើសរើសដោយភាគីនិយោជក :**

ឈ្មោះ : **ឈឹម តិរម្យ**

ហត្ថលេខា: ---------------------------------

THE ARBITRATION COUNCIL

**អាជ្ញាកណ្តាលជ្រើសរើសដោយភាគីកម្មករនិយោជិត :**

ឈ្មោះ : **ស៊ីន គីមស៊ាន**

ហត្ថលេខា: ------------------------------

**ប្រធានក្រុមអាជ្ញាកណ្តាល :**

ឈ្មោះ : **ប៉ែន ប៊ុនឈា**

ហត្ថលេខា: ------------------------------